# CAMBREW LTD

Part of the Carlsberg Group

























# Guinness នាំយក បទពិសោធន៍ដ៏អស្ចារ្យលំដាប់ពិភពលោកមកកាន់កម្ពុជា

House of Guinness ជាព្រឹត្តិការណ៍ពិព័រណ៍អំពីប្រវត្តិដ៏អស្ចារ្យរបស់ស្រាបៀរទឹកខ្មៅ លំដាប់ពិភពលោក Guinness Foreign Extra Stout ដ៏ល្អឥតខ្ចោះ និងមានគុណភាពល្បី ល្បាញទូទាំងពិភពលោក បានមានវត្តមានក្នុងប្រទេសកម្ពុជា។ ព្រឹត្តិការណ៍ដ៏អស្ចារ្យ នេះ ត្រូវបានរៀបចំរយៈពេល ៣ថ្ងៃ កាលពីថ្ងៃទី ២៨ ដល់ ៣០ ខែមេសា ឆ្នាំ២០២៣ នៅផ្សារទំនើប ជីប ម៉ុង ២៧១ មេហ្គាម៉ល។ House of Guinness ជាព្រឹត្តិការណ៍លំដាប់ពិភពលោក ដែលផ្តល់បទពិសោធន៍ដ៏អស្ចារ្យ និងបានទាក់ទាញអ្នកចូលរួមរាប់ម៉ឺននាក់ទូទាំង ពិភពលោក ។

House of Guinness បានធ្វើឱ្យអ្នកចូលរួមមានឱកាសស្វែងយល់កាន់តែច្បាស់អំពីប្រវត្តិដ៏យូរលង់ និងវឌ្ឍនភាពដ៏រីកចម្រើនរបស់ Guinness ព្រមទាំងស្វែងយល់ពីការជ្រើសរើសយ៉ាងសម្រិតសម្រាំងនូវគ្រឿងផ្សំដ៏ល្អឥតខ្ចោះ និងដំណើរការផលិតយ៉ាងហ្មត់ចត់របស់ស្រាបៀរទឹកខ្មៅ Guinness។ មិនតែប៉ុណ្ណោះ Guinness ក៏បានផ្តល់នូវបទពិសោធន៍បែបផែននៃបស្ចឹមប្រទេស និងឱ្យអ្នកចូលរួមផ្ទិតយកទស្សនីយភាពប្លែកភ្នែក ក៏ដូចជាចូលរួមលេងហ្គេមសប្បាយៗ ថតរូបជាមួយបច្ចេកវិទ្យាទំនើប ជាពិសេស បានក្រេបរសជាតិស្រាបៀរស្តោត Guinness ដ៏ឈ្ងុយឆ្ងាញ់ អមដោយការប្រគំតន្ត្រីបែបអឺរ៉ុប និងទទួលបានកាដូអនុស្សាវរីយ៍ពី Guinness ផងដែរ។

Guinness បង្កើតឡើងដំបូងនៅឆ្នាំ ១៧៥៩ ផលិតយ៉ាងល្អឥតខ្ចោះពី ផ្កាហ៊ប ស្រូវសាលី ដំបែ និងវត្ថុធាតុដើមពីប្រទេសអៀរឡង់ បង្កើតបានជាស្រាបៀរទឹកខ្មៅ Guinness Foreign Extra Stout រសជាតិដ៏ជាប់ចិត្ត។ តាមរយៈព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ យើងជឿជាក់ថា ស្រាបៀរ Guinness របស់យើងកាន់តែមានការទទួលស្គាល់ និងគាំទ្រពីអតិថិជនកម្ពុជា។




ដោយបន្តពីយុទ្ធនាការផ្សព្វផ្សាយ «បុរសខ្លាំង ស្រាបៀរខ្លាំង» ដែលមានសន្ទុះគាំទ្រយ៉ាងខ្លាំងក្នុងឆ្នាំ២០២១ ដូចគ្នានឹងយុទ្ធនាការផ្សព្វផ្សាយ «ដៃខ្លាំង ឆន្ទៈខ្លាំង» ក្នុងឆ្នាំ២០២២ ឥឡូវនេះ យើងបានបង្កើនការផ្សព្វផ្សាយស្រាបៀរ ប៊្លែកផេនធ័រ ទៅកាន់អតិថិជនកាន់តែទូលំទូលាយ។ ក្នុងឆ្នាំ២០២៣ យើងនឹងពង្រីកអតិថិជនគោលដៅរបស់យើង ដោយផ្តោតលើការទាក់ទាញអតិថិជនថ្មីៗ និងបន្តរក្សាអតិថិជនដែលមានស្រាប់។

ស្របតាមគោលដៅខាងលើនេះ យើងនឹងផ្សព្វផ្សាយពី “Reasons Why (ហេតុផលសំខាន់ៗ)” ដែលធ្វើឱ្យ ប៊្លែកផេនធ័រ ស័ក្តិសមជាស្រាបៀរស្តោតសម្រាប់អតិថិជនរបស់យើង ដោយមានយុទ្ធនាការប្រចាំត្រីមាសទី១ ៩ទី២ ដែលផ្តោតលើការផ្សព្វផ្សាយ «ផលិតដើម្បីរសជាតិមុតដិត ជាមួយគ្រឿងផ្សំល្អៗ»។

ដូច្នេះក្នុងឆ្នាំនេះ យើងនឹងផ្តោតបន្ថែមលើចំណុចសំខាន់ៗនៃភាពមុតដិតរបស់ស្រាបៀរ ប៊្លែកផេនធ័រ ដូចជា៖

- ផ្សព្វផ្សាយពីគ្រឿងផ្សំគុណភាពខ្ពស់ ដែលសម្រិតសម្រាំងពីជុំវិញពិភពលោក
- បង្កើនការផ្សព្វផ្សាយពីពាណិជ្ជសញ្ញារបស់យើង ដោយផ្តោតលើភាពមុតដិតរបស់ ប៊្លែកផេនធ័រ ដែលមានអត្ថន័យលើសពីរសជាតិ។ យើងក៏សំដៅលើភាពមោះមុត និងការប្តេជ្ញារបស់យើង ដើម្បីទទួលបានប្រណិតភាពផងដែរ
- ធ្វើឱ្យទំនាក់ទំនងជាមួយអតិថិជនកាន់តែមានអត្ថន័យ ដោយអបអរភាពមោះមុតដែលមានក្នុងទឹកចិត្តរបស់ពួកគេ។




អ្វីដែលថ្មីប្លែកនោះ គឺនៅក្នុងខែមេសា យើងបានផលិត និងផ្សព្វផ្សាយវីដេអូអំពីគ្រឿងផ្សំ និងរឿងរ៉ាវដ៏មានអត្ថន័យរបស់ស្រាបៀរ ប៊្លែកផេនធ័រ ដោយមានវត្តមានរបស់តារាចម្រៀងដ៏ល្បីមួយក្នុងប្រទេសកម្ពុជា។

យុទ្ធនាការនេះ ប្រៀបបានដូចជាបេះដូងនៃស្រាបៀរ ប៊្លែកផេនធ័រ ដែលយើងរំពឹងថា នឹងទទួលបាននូវលទ្ធផលដ៏ល្អពីយុទ្ធនាការនេះ។ ចូលរួមអបអរជាមួយស្រាបៀរ ប្លែកផេនធ័រ និងបន្តឈានទៅមុខជាមួយភាពមោះមុតទាំងអស់គ្នាដើម្បីធ្វើឱ្យស្រាបៀរ ប្លែកផេនធ័រ កាន់តែអស្ចារ្យ និងកាន់តែទទួលបានការគាំទ្រ។

# បង្កើតការជួបជុំក៏មានន័យ និងអនុស្សាវរីយ៍ល្អៗក្នុងឆ្នាំថ្មី ជាមួយនឹងស្រាបៀរ អង្គរ រូបរាងថ្មី រសជាតិថ្មីស្រស់




ស្រាបៀរ អង្គរ បានចូលរួមកម្មវិធី សង្ក្រាន្តកោះពេជ្រ ជាមួយ ប៉ិបស៊ី រយៈពេល ៣ ថ្ងៃ ដែលបានធ្វើឡើងនៅមជ្ឈមណ្ឌលពិព័រណ៍ និងសន្និបាតកោះពេជ្រ កាលពីខែមេសា ឆ្នាំ២០២៣។

សង្ក្រាន្តឆ្នាំនេះ អ្នកចូលរួមទទួលបានភាពសប្បាយរីករាយជាមួយនឹងការសម្តែងបែបប្រពៃណី ការប្រគំតន្ត្រីដ៏អស្ចារ្យ ដែលមានការចូលរួមពីតារាចម្រៀងល្បីៗជាច្រើនរូប និងការកម្សាន្តសប្បាយៗជាច្រើនពី ស្រាបៀរ អង្គរ។

គោលបំណងមួយនៃការចូលរួមសង្ក្រាន្តនេះ គឺដើម្បីផ្សព្វផ្សាយ និងបង្កើនការគាំទ្រស្រាបៀរ អង្គរ រូបរាងថ្មី រសជាតិថ្មីស្រស់។ ហើយយើងមានជំនឿយ៉ាងមុតមាំថា ស្រាបៀរ អង្គរ រូបរាងថ្មី រសជាតិថ្មីស្រស់ នឹងទទួលបានការគាំទ្រ និងជំរុញឲ្យពាណិជ្ជសញ្ញាមួយនេះកាន់តែល្បីអស្ចារ្យ។

CAMBREW LTD
Part of the Carlsberg Group

១៥-ឧសភា-២០២៣ /លេខ៖ CAMAPRIL2023#6

# ខេមប្រ៊ូវ អបអរការជួបជុំក្នុងឱកាសចូលឆ្នាំថ្មី ដែលមានតែស្នាមញញឹម និងភាពស្និទ្ធស្នាល




ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ខេមប្រ៊ូវ បានរៀបចំកម្មវិធីអបអរសាទរពិធីបុណ្យចូលឆ្នាំខ្មែរនៅការិយាល័យកណ្តាល និងរោងចក្រផលិតស្រាបៀរ ខេត្តព្រះសីហនុ ជាមួយការរៀបចំនូវកម្មវិធីសាសនា ក៏ដូចជាការលេងល្បែងប្រជាប្រិយខ្មែរ និងការរាំកម្សាន្ត ដើម្បីបង្កើនទំនាក់ទំនងស្និទ្ធស្នាល និងបរិយាកាសដ៏រីករាយនៅកន្លែងធ្វើការ។












ទន្ទឹមនឹងពិធីជួបជុំ អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ខេមប្រ៊ូវ បានផលិតនូវវីដេអូខ្លីមួយ ដើម្បីជាសាររំឭក និងជំរុញទឹកចិត្តប្រជាពលរដ្ឋខ្មែរឱ្យប្រកាន់ខ្ជាប់ជានិច្ច នូវការទទួលខុសត្រូវចំពោះការពិសាគ្រឿងស្រវឹង។

នៅក្នុងវីដេអូនេះ សហសេវិករបស់យើង ក៏បានចែករំលែកពីឆន្ទៈចូលរួមលើកកម្ពស់ការពិសាគ្រឿងស្រវឹង ដោយការទទួលខុសត្រូវជានិច្ច។











ក្នុងនាមជាបុត្រសម្ព័ន្ធមួយរបស់ កាសស្បឺរ គ្រុប និងជាក្រុមហ៊ុនផលិតស្រាបៀរដែលឈានមុខគេមួយ ក្នុងសកម្មភាពទទួលខុសត្រូវសង្គម ខេមប៊្រូវ នឹងបន្តប្តេជ្ញាចិត្តចូលរួមចំណែកបង្កើតវប្បធម៌វិជ្ជមាននៃការពិសាគ្រឿងស្រវឹង   និងជំរុញឱ្យមានវប្បធម៌គ្មានគ្រោះថ្នាក់ទាក់ទងនឹងគ្រឿងស្រវឹង។ យើងចូលរួមអបអររាល់ការជួបជុំក្រុមគ្រួសារ មិត្តភក្តិ និងការដើរកម្សាន្តក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរនេះ ដែលមានតែភាពរីករាយ ស្និទ្ធស្នាល សុវត្ថិភាព និងមានតែស្នាមញញឹម។

# សុខភាព ៥សុវត្ថិភាពនៅកន្លែងធ្វើការ នៅតែជាអាទិភាពនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខេមប្រ៊ូវ










ដើម្បីចូលរួមប្រារព្ធទិវាសុខភាព ៥សុវត្ថិភាពពិភពលោក និងស្របតាមមហិច្ឆតារបស់យើង ក្នុងការបង្កើតវប្បធម៌គ្មានគ្រោះថ្នាក់ ខេមប្រ៊ូវ បានចេញសាររំឭកដល់សហសេវិករបស់យើងគ្រប់រូប អំពី សុខភាព ៥សុវត្ថិភាពរបស់បុគ្គលិក គឺជាអាទិភាពរបស់យើង នៅក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម។







ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងឥតឈប់ឈររបស់យើង ក្នុងការលើកកម្ពស់ការយល់ដឹង និងការពារសុខភាព &សុវត្ថិភាព ក៏ដូចជាចូលរួមប្រារព្ធទិវាសុខភាព &សុវត្ថិភាពពិភពលោក កាលពីថ្ងៃទី២៨ ខែមេសា ខេមប្រ៊ូវ បានរៀបចំកម្មវិធីសុខសុវត្ថិភាពខាងក្នុងក្រុមហ៊ុន ដោយមានការចូលរួមពីសហសេវិកគ្រប់ផ្នែកទាំងអស់នៅការិយាល័យកណ្តាលរាជធានីភ្នំពេញ និងថ្ងៃទី២២ ឧសភា នៅរោងចក្រខេត្តព្រះសីហនុ។ ខេមប្រ៊ូវ ចង់ឃើញសហសេវិករបស់យើងគ្រប់រូប ត្រឡប់ទៅគេហដ្ឋានវិញ ប្រកបដោយសុខ សុវត្ថិភាព ហើយយើងជឿថា ក្រុមគ្រួសារពួកគាត់ ក៏ចង់បានដូច្នេះដែរ។












ស្របតាមគោលដៅចីរភាពថ្មី ស្តីពី បរិស្ថាន សង្គម និងអភិបាលកិច្ច «រួមគ្នាឆ្ពោះទៅកាន់ហេរ្យ៉ូ ៥ លើសពីនេះ (ឬ TTZAB)» មហិច្ឆតា «គ្មានវប្បធម៌គ្រោះថ្នាក់» របស់យើងមានគោលបំណងលុបបំបាត់គ្រោះថ្នាក់ជារៀងរាល់ឆ្នាំ និងបន្តប្តេជ្ញាចិត្តរួមគ្នាឆ្ពោះទៅគោលដៅគ្មានគ្រោះថ្នាក់នៅត្រឹមឆ្នាំ ២០៣០ ។









# អ្នកក៏អាចក្លាយជាបុគ្គលិកប្រចាំខែ! ប៉ុន្តែធ្វើយ៉ាងដូចម្ដេច?







ដើម្បីអាចត្រូវបានជ្រើសរើសជាបុគ្គលិកប្រចាំខែមិនមែនជាកិច្ចការងាយស្រួលឬកាត់ៗនោះទេប៉ុន្តែជាការបញ្ចេញសកម្មភាពដែលស័ក្តិសមនឹងទទួលបានការទទួលស្គាល់។ការអនុវត្តគុណតម្លៃលើភាពអាចសហការគ្នា អាចពឹងពាក់បាន និងទុកចិត្តបាន ជាអ្វីដែលខេមប្រ៊ូវកំពុង និងបន្តធ្វើឥតឈប់ឈរឱ្យកាន់តែល្អឥតខ្ចោះ។

ជាមួយការកសាងឧត្តមភាព គា កញ្ញា អ្នកបច្ចេកទេសផ្នែកសេវាកម្ម និង ហេង ច័ន្ទម៉ូឌីនី ដែលជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុផ្នែកពាណិជ្ជកម្មរបស់យើងបានអនុវត្តគុណតម្លៃនេះពីការសរសេរនៅលើក្រដាស ទៅជាសកម្មភាពក្នុងជីវិតការងារប្រចាំថ្ងៃ ដែលនេះជាកត្តាជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។




" សហការ អាចពឹងពាក់បាន & ជឿទុកចិត្ត "
" COLLABORATIVE, RELIABLE & TRUSTS "

សម្រាប់ កញ្ញា មិនត្រឹមតែជាបុគ្គលគួរឲ្យទុកចិត្តបាន ហើយអាចពឹងពាក់បានប៉ុណ្ណោះទេ កញ្ញា តែងតែបំពេញការងារជាមួយស្មារតីទទួលខុសត្រូវខ្ពស់ ដោយផ្តោតលើលទ្ធផលជាសំខាន់ និងមានភាពចុះសម្រុងជាមួយមិត្តរួមការងារគ្រប់ផ្នែក ក៏ដូចជាជាមួយដៃគូអាជីវកម្ម និងភាគីពាក់ព័ន្ធទាំងអស់។

ចំពោះ ម៉ូឌីនី តែងពិនិត្យការងាររបស់ខ្លួនយ៉ាងល្អិតល្អន់ ដើម្បីធានាថាគ្រប់ជ្រុងនៃទិន្នន័យ និងព័ត៌មាន គឺត្រឹមត្រូវ មុនពេលបញ្ជូនទៅអ្នកគ្រប់គ្រងផ្ទាល់របស់គាត់ និងអ្នកពាក់ព័ន្ធ ។ ការចង់ចេះចង់ដឹងចង់រៀន និងហ៊ានប្រកួតប្រជែងរបស់ ម៉ូឌីនី បានរួមចំណែកដល់ការរីកចម្រើនរបស់ក្រុមហ៊ុនទាំងផ្នែកហិរញ្ញវត្ថុ និងទីផ្សារ។




" សហការ អាចពឹងពាក់បាន & ជឿទុកចិត្ត "
" COLLABORATIVE, RELIABLE & TRUSTS "










នេះជាមូលហេតុដែលពួកគេត្រូវបានមិត្តរួមការងារជ្រើសរើសក្នុងកម្មវិធីបុគ្គលិកប្រចាំខែ។ ដើម្បីអបអរភាពជោគជ័យរបស់ពួកគេ អគ្គនាយកគ្រប់គ្រងខេមប្រ៊ូវ បានសម្តែងការកោតសរសើរដោយបានប្រគល់វិញ្ញាបនបត្រទទួលស្គាល់ និងគូប៉ុងជូនដល់អ្នកទាំងពីរជាការអរគុណ និងលើកទឹកចិត្តឲ្យបន្តអនុវត្តភាពជាគំរូនេះ។

បន្ទាប់ពីការជ្រើសរើសសម្រាប់គុណតម្លៃនេះ គុណតម្លៃបន្ទាប់ គឺសុច្ចរិតភាព ដែលមានភាពស្មោះត្រង់ជាធាតុផ្សំ ដោយប្រកាន់ខ្ជាប់ស្តង់ដារសីលធម៌ខ្ពស់។ តើបុគ្គលិកប្រចាំខែបន្ទាប់ជានរណា?

# កូនៗរបស់សហសេវិកយើង ក៏ចូលរួម ចំណែកក្នុងការលើកកម្ពស់ការយល់ដឹងអំពី សុខភាព និងសុវត្ថិភាព




ការលើកកម្ពស់ការយល់ដឹងអំពី សុខភាព និងសុវត្ថិភាព ក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម គឺជាអាទិភាពរបស់ ខេមប្រ៊ូវ។

ដើម្បីឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់ការយល់ដឹងអំពី សុខភាព និងសុវត្ថិភាព ក៏ដូចជាអបអរសាទរទិវាសុវត្ថិភាពពិភពលោក នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ខេមប្រ៊ូវ បានរៀបចំកម្មវិធីប្រកួតប្រជែងផ្ទាំងគំនូរសុវត្ថិភាព ក្រោមប្រធានបទ «សុខភាព និងសុវត្ថិភាព» សម្រាប់កុមារដែលជាសមាជិកគ្រួសាររបស់សហសេវិកយើង។

សហសេវិកគ្រប់រូប ត្រូវបានលើកទឹកចិត្ត និងអនុញ្ញាតឲ្យណែនាំកូនក្មួយចំនួន ២ រូប ចូលរួមក្នុងការប្រកួតប្រជែងនេះ។ ខេមប្រ៊ូវ ជឿជាក់ថា ការចូលរួមពីកូនក្មួយរបស់សហសេវិក គឺជាចំណែកដ៏សំខាន់ និងមិនអាចខ្វះបាន នៅក្នុងការចែករំលែកសារអប់រំ និងបង្កើតបរិយាកាសការងារមានសុវត្ថិភាព។

ការប្រកួតប្រជែងនេះ គឺសម្រាប់តែកុមារដែលជាសមាជិកគ្រួសារបុគ្គលិកខេមប្រ៊ូវ ដែលមានអាយុច្រើនបំផុត ១៥ ឆ្នាំ ដោយមានលក្ខខណ្ឌដូចជា គំនូរត្រូវតែជាស្នាដៃច្បាប់ដើម និងជាគំនូរពណ៌ ដែលមានសារខ្លីៗទាក់ទងនឹងសុវត្ថិភាព ដូចជាសុវត្ថិភាពតាមដងផ្លូវ សុវត្ថិភាពអគ្គិភ័យ ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) ជាដើម។




យើងបានទទួលស្នាដៃគំនូរប្រកួតប្រជែងជាច្រើន ហើយគណៈកម្មការ និងក្រុមការងារសុខភាព&សុវត្ថិភាព និងប្រធានគ្រប់គ្រងផ្នែកធនធានមនុស្សប្រចាំផ្នែកនីមួយៗ បានវាយតម្លៃយ៉ាងសម្រិតសម្រាំង ជ្រើសរើសយកផ្ទាំងគំនូរដែលមានអត្ថន័យល្អបំផុតចំនួន ១០ ផ្ទាំង សម្រាប់ការវាយតម្លៃចុងក្រោយដោយអគ្គនាយកគ្រប់គ្រង ខេមប្រ៊ូវ។ ផ្ទាំងគំនូរចំនួន ៣ ដែលពោរពេញដោយភាពច្នៃប្រឌិត មានអត្ថន័យ និងខ្លឹមសារ ក៏ដូចជាសោភ័ណភាព បានទទួលពានរង្វាន់ជ័យលាភី និងរង្វាន់ធំ នៅក្នុងកម្មវិធីនេះ។

អ្នកចូលរួមទាំងអស់ ក៏ទទួលបានវិញ្ញាបនបត្រថ្លែងអំណរគុណ ជាមួយនឹងកាដូអនុស្សាវរីយ៍ផងដែរ។

តាមរយៈគំនិតផ្តួចផ្តើមនេះ យើងសង្ឃឹមថា ស្នាដៃគំនូររបស់កូនក្មួយរបស់អ្នក នឹងក្លាយជាសារដ៏សំខាន់បន្ថែមទៀត ជំរុញការចូលរួមលើកកម្ពស់សុខភាព &សុវត្ថិភាព។ យើងនៅតែបន្តបង្កើតបរិយាកាសការងារសុវត្ថិភាពទាំងនៅថ្ងៃនេះ &ថ្ងៃស្អែក និងបន្តដំណើរឆ្ពោះទៅសម្រេចឱ្យបាន គោលដៅចីរភាព «គ្មានវប្បធម៌គ្រោះថ្នាក់» នៅត្រឹមឆ្នាំ ២០៣០។

# ការវិនិយោគលើការពង្រឹងសមត្ថភាពរបស់ អ្នកដឹកនាំយុទ្ធសាស្ត្រអាជីវកម្ម ទាំង៩ ឆ្នាំ២០២៣



ដើម្បីបំពាក់បំប៉ន និងពង្រឹងសមត្ថភាពបន្ថែមដល់អ្នកដឹកនាំ អនុវត្តយុទ្ធសាស្ត្រទាំង៩ ឆ្នាំ២០២៣ របស់យើង ខេមប្រ៊ូវ បានផ្តល់វគ្គបណ្តុះបណ្តាលការគ្រប់គ្រងគម្រោងស្របតាមគំរូរបស់កាសស្ប៊ែរ គ្រុប ក្រោមការយកចិត្តទុកដាក់ខ្ពស់ ពី Vladimir អគ្គនាយកគ្រប់គ្រង ខេមប្រ៊ូវ ។ វគ្គបណ្តុះបណ្តាលនេះ សំដៅដោយចំពោះទៅសហសេវិក ដែលជាអ្នកដឹកនាំការអនុវត្តយុទ្ធសាស្ត្រអាជីវកម្មទាំង៩ ឆ្នាំ២០២៣ ។

វគ្គបណ្តុះបណ្តាលការគ្រប់គ្រងគម្រោងនេះ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៤ ខែមេសា ដោយគ្រូបង្គោលដែលបានជំនាញវិជ្ជាជីវៈ និងមានបទពិសោធន៍យ៉ាងទូលំទូលាយ ក្នុងគោលបំណងផ្តល់ចំណេះដឹង និងបទពិសោធន៍បន្ថែមទៀតដល់អ្នកដឹកនាំយុទ្ធសាស្ត្រអាជីវកម្មទាំង៩ ជាពិសេសផ្តោតលើការគ្រប់គ្រងគម្រោង ក្នុងប្រព័ន្ធកាសស្ប៊ែរ គ្រុប ការរៀបផែនការនៃការធ្វើទំនាក់ទំនង និងយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងគម្រោងប្រកបដោយប្រសិទ្ធភាព។ វគ្គបណ្តុះបណ្តាលនេះ នឹងជួយឱ្យអ្នកដឹកនាំរបស់យើង អាចគ្រប់គ្រងគម្រោងបច្ចុប្បន្ន និងអនាគតប្រកបដោយប្រសិទ្ធភាព។

# ក្រុមហ៊ុនផលិតស្រាបៀរដ៏មានទំនួលខុសត្រូវខ្ពស់ ពឹងផ្អែកលើសហសេរិកដែលពោរពេញដោយអនុលោមភាព និងក្រមសីលធម៌ខ្ពស់




ដើម្បីឲ្យអាជីវកម្មមួយជោគជ័យ ដូចជារោងចក្រផលិតស្រាបៀរលំដាប់អន្តរជាតិរបស់ ខេមប្រ៊ូវ យើងមិនអាចគ្រាន់តែមានសមត្ថភាពក្នុងការយកគ្រឿងផ្សំដ៏ល្អឥតខ្ចោះ និងសមត្ថភាពផលិតស្រាបៀរដ៏មានគុណភាពប៉ុណ្ណោះនោះទេ។ ការងារមួយនេះ ក៏ទាមទារឲ្យមានភាពក្លាហាន ឆន្ទៈមោះមុត ភាពប្រយ័ត្នប្រយែង និងមានសមត្ថភាពដោះស្រាយ និងជៀសវាងបញ្ហានានា ដោយស្របទៅតាមបទប្បញ្ញត្តិជាធរមានផងដែរ។

នៅក្រុមហ៊ុន ខេមប្រ៊ូវ ការបណ្ដុះបណ្ដាលអំពីអនុលោមភាព ទៅកាន់សហសេរិករបស់យើង គឺជារឿងសំខាន់មួយ ដើម្បីឲ្យពួកគេយល់ដឹងអំពីរឿងរ៉ាវនានា នៅក្នុងបរិបទអនុលោមភាពដ៏ស្មុគស្មាញ ដែលបត់បែនទៅតាមកាលៈទេសៈពេលវេលា និងបរិបទផ្សេងៗ។

ដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ សហសេរិកពាក់ព័ន្ធមួយចំនួនរបស់យើង ត្រូវបានអ្នកជំនាញបង្វឹកឱ្យមានភាពឈ្លាសវៃ ទាំងមុនពេលប្រជុំ កំឡុងពេលប្រជុំ និងក្រោយពេលប្រជុំជាមួយសមាគមពាណិជ្ជកម្ម ជាដើម។

# Mitigating risks – during the meeting



**Minutes**: Ensure minutes are taken (either by the association or take them yourself) – these must include a list of participants



**Forbidden topics of discussion**: Do not discuss any competitively sensitive information ("CSI"). This includes: (1) any sensitive information relating to an individual business; (2) how an individual business intends to react to a particular issue or development; and (3) how an individual business views the market, a customer or supplier



**Protesting if discussion strays to risk areas**: If participants begin to discuss CSI or you otherwise suspect non-compliance with competition law, you must (1) protest; (2)leave the meeting; (3) ensure that your objection and departure is recorded in the minutes; (4) report the incident to your local legal representative immediately



**Legal representatives**: From 2022, it is Carlsberg policy that an internal or external lawyer must be present at any high-risk meetings (e.g. Board meetings of trade associations). Depending on the meeting subject, there may be other times where it is appropriate to bring a lawyer to the meeting (with relevant knowledge about competition law)

បញ្ហាមួយចំនួនដែលធ្លាប់កើតមានរួចមកហើយ គឺកើតចេញតាមរយៈកិច្ចប្រជុំសមាគមពាណិជ្ជកម្ម ដែលកិច្ចប្រជុំរបៀបនេះមានហានិភ័យខ្ពស់ និងអាចផ្ទុយពីច្បាប់ស្តីពីការប្រកួតប្រជែង។

ឧទាហរណ៍ នៅពេលដែលយើងចូលរួមកិច្ចប្រជុំជាមួយធុរជនដទៃទៀត ដែលមានទាំងដៃគូប្រកួតប្រជែងផងដែរនោះ យើងអាចប្រឈមនឹងហានិភ័យនៃការបង្កើតជាការឃុបឃិតធុរកិច្ចសម្ងាត់អ្វីមួយ (cartel) ។

ការឃុបឃិតធុរកិច្ចសម្ងាត់ មានវត្តមានច្រើនគួរសមដែរ ដែលអាចកើតមានឡើងតាមរយៈកិច្ចប្រជុំសមាគមពាណិជ្ជកម្ម។ បើរឿងនេះកើតឡើង នឹងមានការស៊ើបអង្កេតយ៉ាងតឹងរ៉ឹង ខាតបង់ពេលវេលា និងធនធានហិរញ្ញវត្ថុយ៉ាងសន្ធឹកសន្ធាប់ក៏ដូចជាប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន។

ក្នុងករណីនេះដែរ សមាជិកក្រុមធុរកិច្ចសម្ងាត់ អាចមានគំនិតមិនល្អ ដោយអាចរាយការណ៍ទៅអាជ្ញាធរអំពីរឿងនេះ រួចគេអាចសុំការអត់ឱន ឬបន្ធូរបន្ថយទោសចំពោះខ្លួនឯងពីអាជ្ញាធរ។ ជាលទ្ធផល យើងអាចប្រឈមការផាកពិន័យ ឬទណ្ឌកម្មគ្រប់ទម្រង់ ដែលនេះមិនមែនជាអ្វីដែលក្រុមហ៊ុនមានទំនួលខុសត្រូវដូចយើង ចង់ឲ្យកើតមានឡើងឡើយ។

ដើម្បីកាត់បន្ថយហានិភ័យទាំងនេះ បុគ្គលដែលចូលរួមប្រជុំនៅក្នុងសមាគមពាណិជ្ជកម្ម ត្រូវតែជាបុគ្គលដែលត្រូវបានក្រុមហ៊ុនចាត់តាំងឡើង ដោយសេចក្តីទុកចិត្ត។ បទប្បញ្ញត្តិគ្រប់គ្រងសមាគម ត្រូវតែមានការប្តេជ្ញាខ្ពស់ក្នុងការគោរព និងអនុលោមតាមច្បាប់ស្តីពីការប្រកួតប្រជែង។

នេះ គ្រាន់តែជាឧទាហរណ៍មួយ ដែលសបញ្ជាក់ឲ្យឃើញថា ក្រុមហ៊ុនផលិតស្រាបៀរដ៏មានទំនួលខុសត្រូវ មិនមែនគ្រាន់តែទាមទារអ្នកផលិតដ៏ចំណាននោះទេ តែគេក៏ត្រូវការក្រុមការងារអនុលោមតាមច្បាប់ដ៏ចំណាប់ផងដែរ។

## Mitigating risks – after the meeting




8

Carlsberg Group

CAMBREW LTD

Part of the Carlsberg Group

# គ្មានការពិសាគ្រឿងស្រវឹង ដោយគ្មានទំនួលខុសត្រូវ

# និងគ្មានវប្បធម៌គ្រោះថ្នាក់


No. 1881, Russian Boulevard, Phum Ta gnoun, Sangkat Kakab, Khan Posenchey, Phnom Penh, Kingdom of Cambodia

+855 (0) 16 880 695

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

Carlsberg Group
Carlsberg Cambodia